# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ជស/រកត/១០៩៥/០១

# ព្រះរាជក្រឹត្យ
## យើង
## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣
- យោងតាមព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣
- យោងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រីទាំងពីរ និងអំពីសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

# ត្រាស់បង្គាប់

**មាត្រា ១** : គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើត និងរៀបរៀងតាមប្រភេទ និងតាមឋានានុក្រម ដូចខាងក្រោមនេះ ៖

ក- ប្រភេទមាតុប្រទេស ៖

១- មេដាយជាតូបការៈ

២- មេដាយព្រះរាជាណាក្រកម្ពុជា មាន ៥ ថ្នាក់ ៖ មហាសេរីវឌ្ឍន៍ មហាសេនា - ធិបឌិន្ទ - សេនា - អស្សឫទ្ធិ

៣- មេដាយឯករាជ្ជាតិ

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណូបការៈដ៏ឧត្តុងឧត្តមក្នុងការបំរើមាតុប្រទេស ដើម្បីបុព្វហេតុឯករាជ្យ សាមគ្គីភាព ប្រជាធិបតេយ្យ និង សន្តិភាពជាតិ

តាមរយៈព្រះរាជក្រឹត្យក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ដោយព្រះរាជតំណាង ។

ខ- ប្រភេទព្រះរាជបល្ល័ង្គ

១- មេដាយរាជសម្បត្តិ

២- មេដាយ រដ្ឋកាល មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

៣- មេដាយ អនុស្សរា

គ្រឿងឥស្សរិយយសប្រភេទនេះ សំរាប់បំពាក់ជូនវរជនដែលមានគុណបំណាច់ចំពោះព្រះរាជបល្ល័ង្គ ចំពោះព្រះមហាក្សត្រផ្ទាល់ ចំពោះព្រះរាជវង្សានុវង្ស ព្រះមហាក្សត្រ ឬជាអនុស្សរីយ៍របស់ព្រះមហាក្សត្រ ។

ការផ្ដល់ និង បំពាក់គ្រឿងឥស្សរិយយសទាំងនេះ ត្រូវសំរេចដោយព្រះរាជតំរិះផ្ទាល់របស់ព្រះមហាក្សត្រ តាមរយៈក្រឹត្យបរមរាជវាំង ។

គ- ប្រភេទការពារជាតិ :

១- មេដាយសេនាជ័យសិទ្ធ

២- មេដាយការពារជាតិ មាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ

គ្រឿងឥស្សរិយយសទាំងនេះ សំរាប់បំពាក់ជូនដល់ពលទាហាន នាយទាហាន នៃ កងកម្លាំងប្រដាប់អាវុធ ឬ នគរបាលដែលមានស្នាដៃឆ្នើមពិសេសក្នុងសង្គ្រាម ឬកិច្ចការពារព្រំដែន និងការពារសន្តិសុខជូនជាតិមាតុភូមិតាមរយៈ ព្រះរាជក្រឹត្យ ក្រោយពីការសំរេចរបស់គណៈរដ្ឋមន្ត្រី ហើយ ត្រូវប្រទានដោយព្រះមហាក្សត្រ ឬ ព្រះរាជតំណាង ។

ឃ- ប្រភេទចំរុះ

១- មេដាយសហមេត្រី មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនអង្គទូត ឬ តំណាងប្រទេសជាមិត្តដែលបានបំពេញការងារ ដើម្បីជាប្រយោជន៍ ដល់ចំណងមិត្តភាព ប្រទេសទាំងពីរ ។

២- មេដាយសុវត្ថារា មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងវិស័យ កសិកម្មនិងសេដ្ឋកិច្ច ។

៣- មេដាយមុនីសារាភ័ណ្ឌ មាន ៣ ថ្នាក់ : ធិបឌិន្ទ, សេនា, អស្សឫទ្ធិ សំរាប់បំពាក់ជូនបុគ្គលដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ ក្នុងវិស័យសិក្សាធិការ អក្សរសាស្ត្រវិទ្យាសាស្ត្រ វិចិត្រសិល្បៈ សង្គមកិច្ច ឬ វិស័យផ្សេង ៗទៀត ។

៤- មេដាយការងារមាន ៣ ថ្នាក់ : មាស , ប្រាក់ , សំរិទ្ធ សំរាប់បំពាក់ជូនបុគ្គលដែលមានថ្វីដៃ ក្នុងការងារផ្នែករដ្ឋបាល ឬ ក្នុងវិស័យឯកជន ។

៥- មេដាយស្ថាបនាជាតិមាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនសប្បុរសជន ដែលបានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួនជួយកសាងជាតិ ឬស្ថាបនា សមិទ្ធិជាប្រយោជន៍សាធារណៈ ។

៦- មេដាយខេមរាកីឡាឫទ្ធិ មាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនកីឡាករដែលមានស្នាដៃឆ្នើមក្នុងវិស័យកីឡាជាតិ ឬអន្តរជាតិ ដែលបាននាំមកនូវកិត្តិយសដល់ប្រទេសជាតិ ។

៧- មេដាយស្ត្រីវឌ្ឍនា មាន ៣ ថ្នាក់ : មាស , ប្រាក់, សំរិទ្ធ សំរាប់បំពាក់ជូនស្ត្រី ឬ បុរសដែលមានគុណូបការៈខ្ពង់ខ្ពស់ក្នុងការលើកតំកើងបុព្វហេតុស្ត្រី ។

គ្រឿងឥស្សរិយយសប្រភេទចំរុះនេះ ត្រូវសំរេចតាមរយៈអនុក្រឹត្យនិងបំពាក់ដោយនាយករដ្ឋមន្ត្រី ឬ តំណាង ។

**មាត្រា ២** : រូបភាពលក្ខណៈសញ្ញាផ្សេងៗ នៃឥស្សរិយយស និង ប្រកាសនីយប័ត្រគ្រឿងឥស្សរិយយសទាំងនេះ ត្រូវយកតាមគំរូដែលបានកំណត់ក្នុងព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៦៣ ។

**មាត្រា ៣** : រៀងរាល់ដំណាច់ឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចតាមក្រសួង ឬ តាមអង្គភាពនីមួយៗ មានភារកិច្ចស្រង់បញ្ជីឈ្មោះ វរជនដែលត្រូវស្នើរដ្ឋាភិបាល ដើម្បីសំរេចជូនមេដាយ ដោយមានបញ្ជាក់ផងដែរនូវ ទឡ្ហីករណ៍ចំពោះករណី ផ្ទាល់វរៈជនម្នាក់ ៗ ។
ក្នុងករណីពិសេស បន្ទាន់ និង ចាំបាច់ នាយករដ្ឋមន្ត្រីអាចនឹងស្នើរៀបចំពិធីបំពាក់ឥស្សរិយយសនេះជាមុន រួចរៀបចំសំណុំបែបបទ ស្នើសុំជាខាងក្រោយ ។

**មាត្រា ៤** : គ្រឿងឥស្សរិយយស ពុំអាចផ្តល់ជូនឥស្សរជនមួយរូបលើសពីមួយដង ក្នុងមួយឆ្នាំបានឡើយ ។ តែមេដាយ ការពារជាតិ ឬ មេដាយស្ថាបនាជាតិមិនត្រូវគិតបញ្ចូលទេ ។

**មាត្រា ៥** : រាជរដ្ឋាភិបាលត្រូវផលិតមេដាយ និង ត្រូវមានសារាចរលំអិតបន្ថែមទៀតដើម្បីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ច គ្រប់ថ្នាក់ អំពីបែបបទ នៃការរៀបចំសំណើសុំគ្រឿងឥស្សរិយយស ។

**មាត្រា ៦** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៧** : នាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៨** : ព្រះរាជក្រឹត្យនេះមានអានុភាពគតិយុត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥
ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់
**ប្រមុខរដ្ឋស្តីទី**
**ហត្ថលេខា**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| **ព្រះហស្តលេខា** | **ហត្ថលេខា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

បានបង្គំទូលថ្វាយនិងជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រីទី១ និងទី២
សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
**ហត្ថលេខា**
**សុខ អាន** **វ៉េង សិរីវុឌ្ឍ**

លេខ ៥៧ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ណាឌី តាន់**